**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៤ សហវ.ប្រក. រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធ និងអាករ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ការលើកលែងពន្ធ និងអាករនាំចូល ត្រូវបានផ្តល់ចំពោះមុខទំនិញនៃអ្នកនាំចូលមួយចំនួន ស្របតាមបញ្ញត្តិមាត្រា ២៦ នៃច្បាប់ស្តីពីគយ ។

ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករនាំចូលមានដូចខាងក្រោម៖

ក- ទំនិញសម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ ដោយមានការបញ្ជាក់ពីប្រធានបេសកកម្ម និងពីក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ ។

ខ- ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គការដូចបានរៀបរាប់នៅក្នុងវាក្យខណ្ឌ ក នៃប្រការនេះ ។ ការអនុវត្តនូវវាក្យខណ្ឌនេះ និងវាក្យខណ្ឌ ក នៃប្រការនេះត្រូវផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ និងគោលការណ៍បដិការ រវាង រដ្ឋាភិបាលពាក់ព័ន្ធ ។

គ- ទំនិញមានដើមកំណើតកម្ពុជា ឬទំនិញនាំចូលដែលបានបង់ពន្ធ និងអាកររួច ដែលចេញពីដែនគយហើយត្រូវនាំចូលត្រឡប់ពីបរទេសមកវិញដោយពុំមានការបង្កើនតម្លៃ ។

ឃ- ទំនិញដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ។

ង- ទំនិញជាអំណោយសម្រាប់មនុស្សធម៌ ទំនិញសម្រាប់ការស្រាវជ្រាវ និងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម មឈូសដែលមានសាកសពមនុស្ស ។

ច- ទំនិញនាំចូលដែលមានតម្លៃ និងបរិមាណច្បាស់លាស់មួយចំនួនតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ដែលនាំចូលដោយអ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែនត្រូវលើកលែងពន្ធ និងអាករ ។

ឆ- ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬផ្ទេរមធ្យោបាយដឹកជញ្ជូន ។

ជ- សម្ភារៈប្រើប្រាស់ក្នុងផ្ទះ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀតលើកលែងតែយានយន្តដែលនាំចូលដោយ បុគ្គលដែលផ្លាស់ប្តូរទៅ

ស្ពានមកកម្ពុជាក្នុងបរិមាណដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ។

ឈ- បរិក្ខារឧស្សាហកម្ម និងសម្ភារៈផ្សេងទៀតដែលជាតម្រូវការសម្រាប់ប្រតិបត្តិការនិងការថែរក្សាបរិក្ខារទាំងនេះ ដែលប្រើប្រាស់នៅក្នុងសមុទ្រសម្រាប់ការរុករក និងទាញយកផលិតផលគេលសិលា និង សារធាតុខនិជនិងសរីរាង្គផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ញ- ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បុគ្គលដែលនាំចូលទំនិញក្រោមបញ្ញត្តិនៃកថាខណ្ឌខាងលើត្រូវផ្តល់នូវឯកសារជាកស្តុតាងដល់រដ្ឋបាលគយថា ទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានការលើកលែងពន្ធ និងអាករ ។

បុគ្គល ឬអង្គការនានាដែលមានបំណងស្នើសុំការលើកលែងពន្ធ និងអាករលើទំនិញនាំចូលក្រោមបញ្ញត្តិកថាខណ្ឌ ក និងកថាខណ្ឌ ខ ខាងលើត្រូវមានការអនុញ្ញាតជាមុនពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិស្របតាមនីតិវិធីជាធរមាន ។

បុគ្គលដែលមានបំណងនាំចូលទំនិញក្រោមបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមនីតិវិធី និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.-**

ការលើកលែងជាភាគនូវពន្ធ និងអាករនាំចូល ត្រូវបានផ្តល់ចំពោះមុខទំនិញ និងអ្នកនាំចូលមួយចំនួនស្របតាមបញ្ញត្តិមាត្រា ២៧ នៃច្បាប់ស្តីពីគយ ។

ទំនិញដែលត្រូវបានលើកលែងជាភាគនូវពន្ធ និងអាករនាំចូលមានដូចខាងក្រោម ៖

ក- ទំនិញ និងសម្ភារៈដែលត្រូវបានលើកលែងជាភាគនូវពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃច្បាប់ណាមួយជាធរមាន ។

ខ- ពូជដំណាំ និងពូជសត្វសម្រាប់កសិកម្ម ។

គ- ទំនិញដែលនឹងត្រូវទទួលការជួសជុល ការកែច្នៃ ឬពិសោធន៍

ឃ- ទំនិញដែលបាននាំចូលវិញតាមសភាពដើម ។

ង- ទំនិញដែលនាំចូលដោយរដ្ឋាភិបាលដើម្បីជាប្រយោជន៍សាធារណៈ និងទំនិញនាំចូលសម្រាប់របបប្រវេសកាលិក

ច- ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

បុគ្គលដែលនាំចូលទំនិញក្រោមបញ្ញត្តិនៃប្រការនេះត្រូវផ្តល់នូវឯកសារជាកស្តុតាងដល់រដ្ឋបាលគយថា ទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានការលើកលែងជាភាគនូវពន្ធ និងអាករ ។

**ប្រការ ៣.-**

ការផ្គត់ផ្គង់ស្បៀងអាហារ និងវត្ថុបម្រុងទុកចាំបាច់សម្រាប់នាវាត្រូវអនុវត្តតាមលក្ខខណ្ឌដូចតទៅ ៖

- ស្បៀងអាហារ និងវត្ថុបម្រុងទុកសម្រាប់នាវាមកដល់ពីបរទេសដែលមិនលើសពីការចាំបាច់សម្រាប់ក្រុមនាវិក និងអ្នកដំណើរពុំត្រូវជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករនាំចូលឡើយបើវត្ថុទាំងនេះរក្សាទុកនៅក្នុងនាវា ។ មន្ត្រីគយមានសមត្ថកិច្ចអាចបិទត្រាគយលើឃ្លុប និងបន្ទប់ខ្លះដែលមានស្បៀងអាហារ និងវត្ថុបម្រុងទុកដូចនេះ ។

- ស្បៀងអាហារ និងវត្ថុបម្រុងទុកសម្រាប់នាវាអាចត្រូវបានលើកចេញពីនាវាចូលដែនគយបានតែក្រោយពេលធ្វើប្រតិវេទន៍គយ ព្រមទាំងបានបង់ពន្ធ និងអាករដែលជាប់ ។

- បើចំនួនស្បៀងអាហារ និងវត្ថុបម្រុងទុកសម្រាប់នាវាមិនលើសពីតម្រូវការជាមូលដ្ឋានដើម្បីទៅបរទេសណាមួយ ពុំត្រូវជាកម្មវត្ថុនៃការជាប់អាករនាំចេញ

- ទោះក្នុងករណីណាក៏ដោយចំនួនសមាជិកក្រុមនាវិក និងអ្នកដំណើរ ចំនួន និងប្រភេទស្បៀងអាហារ និងវត្ថុបម្រុងទុកសម្រាប់នាវាដើម្បីចេញដំណើរត្រូវ

ចុះក្នុងលិខិតផុតរបស់នាវាដែលត្រូវមានការឯកភាពពីមន្ត្រីគយមានសមត្ថកិច្ច

- បរិមាណនៃស្បៀងអាហារ និងវត្ថុបម្រុងទុកដែលមានចែងក្នុងប្រការនេះ ដែលមន្ត្រីគយមានសមត្ថកិច្ចបានពិនិត្យឃើញថា លើសពីតម្រូវការសម្រាប់នាវាត្រូវជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករ ។

- សម្រាប់នាវាកម្ពុជាដែលត្រឡប់មកកាន់កំពង់ផែណាមួយនៃដែនគយវិញនាវាបតីត្រូវបង្ហាញឡើងវិញនូវលិខិតផុតរបស់នាវាដែលខ្លួនបានកាន់នៅពេលចេញដំណើរ ។ ស្បៀងអាហារ និងវត្ថុបម្រុងទុកដែលនៅសល់ត្រូវបានអនុញ្ញាតឱ្យយកចេញពីនាវាដោយលើកលែងពន្ធ និងអាករ ។

**ប្រការ ៤.-**

ការផ្គត់ផ្គង់ស្បៀងអាហារ និងវត្ថុបម្រុងទុកចាំបាច់សម្រាប់អាកាសយានត្រូវអនុវត្តតាមលក្ខខណ្ឌដូចតទៅ ៖

- ស្បៀងអាហារនិងវត្ថុបម្រុងទុកសម្រាប់អាកាសយានមកដល់ពីបរទេសដែលមិនលើសពីការចាំបាច់ ពុំត្រូវជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករនាំចូលឡើយ បើវត្ថុទាំងនេះរក្សាទុកនៅក្នុងអាកាសយាន ។

- ស្បៀងអាហារ និងវត្ថុបម្រុងទុកសម្រាប់អាកាសយានអាចត្រូវបានយកចេញពីអាកាសយានចូលដែនគយបានតែក្រោយពេលធ្វើប្រតិវេទន៍គយ ព្រមទាំងបានបង់ពន្ធ និងអាករដែលជាប់ ។

- បើចំនួនស្បៀងអាហារ និងវត្ថុបម្រុងទុកសម្រាប់អាកាសយានមិនលើសពីតម្រូវការជាមូលដ្ឋានដើម្បីទៅបរទេសណាមួយ ពុំត្រូវជាកម្មវត្ថុនៃការជាប់អាករនាំចេញទេ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៦
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ